**Embassy of Japan**
**in the Kingdom of Cambodia**

# Press Release

No. 35 PR-23/EoJ 11 October 2023

## Asian International Children's Film Festival 2023
## -Result of 12th Preliminary In-Country Contest in Cambodia-

The 12th Preliminary In-Country Contest in Cambodia for the "Asian International Children's Film Festival 2023" was successfully held on Monday, 9 October 2023 at the Cambodia-Japan Cooperation Center (CJCC).

This preliminary contest was organized by the Embassy of Japan in Cambodia in cooperation with the Ministry of Education, Youth and Sport and CJCC. The theme of the films this year is **"What I want"**. 13 films by high school students were pre-selected and screened at the contest.

This Festival started in Japan in 2007, and since then, it has been organized every year. Cambodian students have been invited to this Festival since 2009. This year, 9 Students of the 3 winning groups from Cambodia (see below) will be invited to Japan under the "Japan-East Asia Network of Exchange for Students and Youths" 2023 program (JENESYS 2023). They will participate in the final round of the Festival as representatives of Cambodia together with students from Japan, other ASEAN countries, and Timor-Leste, in Minami Awaji City, Hyogo Prefecture, Japan on 16 December 2023.

We hope that the Cambodian students will be successful in the Festival and enjoy building up friendship with other participants.

***The 3 films selected in the In-Country Contest and nominated to the final round***

| ***Prize*** | ***Name of students*** | ***Title of films*** | ***Name of high schools*** |
|---|---|---|---|
| 1st | Ms. Rath Yaroo | What I want | Pich Chenda High School (Battambang) |
| | Ms. Pov Sovannaroth | | |
| | Mr. Nov Terayu | | |
| 2nd | Ms. Sem Sreyleap | What I want is not just for myself | Net Yang High School (Battambang) |
| | Ms. Sambath Pheana | | |
| | Ms. Leng Chansreyneang | | |
| 3rd | Mr. Chum Monyratanak | What I truly wanted | Sovannaphumi School (Takeo) |
| | Mr. Chhunpan Somethkolboth | | |
| | Mr. San Maovisal | | |



Group photo of 3 winning groups and judges

For further information, please contact the Culture and Information Section of the Embassy of Japan at 023 217 161 (1121) or email to info.jpn@pp.mofa.go.jp.

# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

លេខៈ 35 PR-23/EoJ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣

## មហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីឆ្នាំ២០២៣
## ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា

ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជាលើកទី១២ នៃមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីឆ្នាំ២០២៣ បានប្រព្រឹត្តទៅដោយជោគជ័យនៅថ្ងៃចន្ទ ទី០៩ ខែតុលា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)។

ការប្រកួតនេះ ត្រូវបានរៀបចំឡើងដោយស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងCJCC។ ប្រធានបទដែលត្រូវបកស្រាយក្នុងឆ្នាំនេះគឺ«**អ្វីដែលខ្ញុំចង់បាន (What I want)**»។ មានភាពយន្តចំនួន១៣រឿងដែលផលិតដោយសិស្សវិទ្យាល័យត្រូវបានជ្រើសរើស សម្រាប់ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រនេះ។

មហោស្រពភាពយន្តនេះ បានចាប់ផ្តើមនៅប្រទេសជប៉ុនតាំងពីឆ្នាំ២០០៧មកម្លេះ ហើយចាប់តាំងពីពេលនោះមក គឺមហោស្រពនេះបានចាប់ផ្តើមប្រារព្ធឡើងជារៀងរាល់ឆ្នាំ។ ចំណែកសិស្សានុសិស្សកម្ពុជាវិញត្រូវបានអញ្ជើញអោយចូលរួមក្នុងមហោស្រពនេះតាំងពីឆ្នាំ២០០៩។ ឆ្នាំនេះ សិស្ស៣ក្រុមដែលមានចំនួនសរុប៩រូប (ឈ្មោះមានភ្ជាប់នៅតារាងខាងក្រោម) នឹងត្រូវបានអញ្ជើញទៅកាន់ប្រទេសជប៉ុន ក្រោមកម្មវិធីJENESYS2023 ជាមួយសិស្សមកពីបណ្តាប្រទេសអាស៊ានទាំង១០ ព្រមទាំង ទីម័រខាងកើត សម្រាប់វគ្គផ្តាច់ព្រ័ត្រនៅទីក្រុងមិណាមិ អាវ៉ាជិ ខេត្តហ្យូហ្គុ ប្រទេសជប៉ុន នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣។

យើងសង្ឃឹមថាសិស្សកម្ពុជានឹងទទួលបានជោគជ័យនៅក្នុងកម្មវិធីមហោស្រពខាងមុខនេះ ព្រមទាំងសប្បាយរីករាយកសាងមិត្តភាពជាមួយអ្នកចូលរួមដទៃទៀត។

រឿងខ្លីចំនួន៣រឿងដែលបានជ្រើសរើសចូលរួមក្នុងវគ្គផ្តាច់ព្រ័ត្រនៃមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ី ឆ្នាំ២០២៣ មានដូចខាងក្រោម៖

| *ក្រុមជ័យលាភី* | *ឈ្មោះជ័យលាភី* | *ចំណងជើងរឿង* | *វិទ្យាល័យ* |
|---|---|---|---|
| លេខ១ | បេក្ខនារី រ៉ាត់ យ៉ារ៉ូ<br>បេក្ខនារី ពៅ សុវណ្ណារតន៍<br>បេក្ខជន នៅ ថិរ៉ាយុ | អ្វីដែលខ្ញុំចង់បាន | វិទ្យាល័យពេជ្រចិន្តា (ខេត្តបាត់ដំបង) |
| លេខ២ | បេក្ខនារី ស៊ិម ស្រីលៀប<br>បេក្ខនារី សម្បត្តិ ភាណា<br>បេក្ខនារី ឡេង ចាន់ស្រីនាង | អ្វីដែលខ្ញុំចង់បាន មិនមែនសម្រាប់តែខ្លួនឯង | វិទ្យាល័យនេតយ៉ង់ (ខេត្តបាត់ដំបង) |
| លេខ៣ | បេក្ខជន ជុំ មុនីរតនៈ<br>បេក្ខជន ឈុនប៉ាន់ សុមេធកុលបុត្ត<br>បេក្ខជន សន ម៉ៅវិសាល | អ្វីដែលខ្ញុំចង់បាន ពិតប្រាកដ | សាលារៀនសុវណ្ណភូមិ (ខេត្តតាកែវ) |



រូបថតជាក្រុមរបស់ក្រុមជ័យលាភី៣ក្រុម និងគណៈកម្មការដាក់ពិន្ទុ

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរស័ព្ទលេខ ០២៣ ២១៧ ១៦១ (១១២១) ឬ អ៊ីម៉ែល info.jpn@pp.mofa.go.jp ។